**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងមហាផ្ទៃ
សាលាខេត្តព្រៃវែង
លេខ ០០៥/សជណ/១១

# សេចក្តីជូនដំណឹង
## ស្តីពី
## ពន្ធតែមប្រើសារពើពន្ធ

- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ ចុះថ្ងៃទី ១១ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការកែលំអនិងបំពេញបន្ថែមអនុក្រឹត្យលេខ ១៩ អនក្រ ចុះថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ១៩៩១ ស្តីពីការប្រមូលពន្ធតែមប្រើសារពើពន្ធ
- បានឃើញប្រកាសលេខ ០៣៧ ប្រក.កហវ.ពដ ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ១៩៩១ ស្តីពីការណែនាំអនុវត្តអនុក្រឹត្យ ស្តីពីការប្រមូលពន្ធតែមប្រើសារពើពន្ធ
- បានឃើញប្រកាសលេខ ៣៤៦ ប្រក.កហវ.ពដ ចុះថ្ងៃទី ២៦ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការណែនាំអនុវត្ត ស្តីពីការប្រមូលពន្ធតែមប្រើសារពើពន្ធ

អភិបាលនៃគណៈអភិបាលខេត្តសូមជូនដំណឹងថា៖

១- ពន្ធតែមប្រើកំណត់លើលិខិតរដ្ឋបាល លិខិតតុលាការ លិខិតក្រៅតុលាការ និង ប័ណ្ណប្រកាស។

២- ការប្រមូលពន្ធតែមប្រើមានពីរប្រភេទ៖
   ក. ការប្រមូលដោយប្រើសន្លឹកតែមប្រើបិទលើលិខិតរដ្ឋបាល លិខិតតុលាការ លិខិតក្រៅតុលាការ។
   ខ. ការប្រមូលដោយប្រើបង្កាន់ដៃពន្ធលើប័ណ្ណប្រកាសមាន៖
      - ប័ណ្ណប្រកាសផ្សាយពាណិជ្ជកម្មធ្វើដោយក្រដាស់ ក្រណាត់ ឬ វត្ថុផ្សេងៗ
      - ផ្លាកអាជីវកម្មដ្ឋាននានា និង ផ្ទាំងអក្សរ ផ្ទាំងរូបភាពលើកក្នុងគោលបំណងផ្សាយពាណិជ្ជកម្ម។

៣- ហាមភ្នាក់ងាររអាជ្ញាធរមានសមត្ថកិច្ចទទួល ឬ ចេញលិខិតត្រូវជាប់ពន្ធដែលមិនបានបង់ពន្ធតែមប្រើ។

៤- សហគ្រាសដែលត្រូវជាប់ពន្ធតែមប្រើលើប័ណ្ណប្រកាសរយៈពេលវែង ត្រូវប្រកាសបង់ពន្ធចាប់ពីថ្ងៃទី ១មករា ដល់ថ្ងៃទី ៣១ ខែមិនានៃឆ្នាំប្រមូលពន្ធ។

៥- ករណីមិនព្រមបង់ពន្ធតែមប្រើ ត្រូវទទួលរងអនុវត្តវិធានការតឹងទារបំណុលពន្ធ។

ទទួលបាននូវសេចក្តីជូនដំណឹងនេះ អភិបាលនៃគណៈអភិបាលខេត្តសង្ឃឹមថា ភ្នាក់ងាររអាជ្ញាធរមានសមត្ថកិច្ចទទួល ឬចេញលិខិត ព្រមទាំងម្ចាស់សហគ្រាស នឹងយកចិត្តទុកដាក់បំពេញកាតព្វកិច្ចបង់ពន្ធ តាមការណែនាំជាមិនខានឡើយ។

ព្រៃវែង ថ្ងៃទី ០១ ខែធ្នូ ឆ្នាំ២០១១
**អភិបាលនៃគណៈអភិបាលខេត្ត**

**អ៊ុំ សាមី**

**កន្លែងទទួល៖**
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានពន្ធដារ
- ក្រុមប្រឹក្សាខេត្តព្រៃវែង
  "គោរពជូនជ្រាប"
- សាលាស្រុក-ក្រុង
- សាខាពន្ធដារខេត្ត
- និងស្ថាប័នពាក់ព័ន្ធ
  "ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ